**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**


**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**"រ.ទ.ស.ភ"**
លេខ ១៨២.ស.ជ.ណ


ភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៧

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់ខ្សាច់ទន្លេ និង នាឡិកាទឹកមេកានិក-ខ្នាតតូច

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់ដូចខាងក្រោមៈ

១-កញ្ចប់"ក": ការផ្គត់ផ្គង់ខ្សាច់ទន្លេ

២-កញ្ចប់"ខ": ការផ្គត់ផ្គង់នាឡិកាទឹកមេកានិក-ខ្នាតតូច

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ក្នុងមួយច្បាប់តម្លៃ ៥០០,០០០រៀល សម្រាប់កញ្ចប់"ក" និង៦០០,០០០រៀល សម្រាប់កញ្ចប់"ខ"។

កាលបរិច្ឆេទឈប់ទទួល និង បើកសំណើដេញថ្លៃគឺ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ កញ្ចប់"ក"វេលាម៉ោង ១៤:៣០នាទី និង កញ្ចប់"ខ"វេលាម៉ោង ១៤:៥០នាទី នៅអគារអង្គភាពលទ្ធកម្ម នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

អ្នកដេញថ្លៃមានសិទ្ធិជ្រើសរើសកញ្ចប់មួយ ឬទាំងអស់។ ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ(ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**អគ្គនាយក**

**ស៊ឹម ស៊ីថា**

<u>ចម្លងជូនៈ</u>

-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

-អង្គភាពប្រឆាំងអំពើពុករលួយ

"ដើម្បីជ្រាបជាព័ត៌មាន"

-ឯកសារ-កាលប្បវត្តិ